# ការកែលម្អស្ថានភាពពន្ធនាគារ និងការធានាការពារសិទ្ធិអ្នកទោសនៅកម្ពុជា

**ចាប់ពីឆ្នាំ២០០៨ មក ការិយាល័យ OHCHR ប្រចាំកម្ពុជា បាន និងកំពុងធ្វើការជាមួយអគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីកែលម្អស្ថានភាពពន្ធនាគារ បង្ការទារុណកម្ម និងធានាការពារសិទ្ធិអ្នកទោស និងជនជាប់ឃុំ ចំនួន ១៤.៧០០ នាក់ នៅកម្ពុជា។**




អ្នកទោសកំពុងធ្វើលំហាត់ប្រាណយកខ្យល់អាកាសដោយសេរី

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) ប្រចាំកម្ពុជា ធ្វើការងារដើម្បីពង្រឹងស្ថានភាពរស់នៅរបស់អ្នកទោស និងជនជាប់ឃុំក្នុងពន្ធនាគារ លើកម្ពស់ ស្ថានភាពគតិយុត្ត និងវិជ្ជាជីវៈរបស់មន្ត្រីពន្ធនាគារ ធានាឲ្យមានការដាក់បញ្ចូលបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ទៅក្នុងក្របខ័ណ្ឌច្បាប់ជាតិ ដែលគ្រប់គ្រងលើការប្រព្រឹត្តទៅលើអ្នកទោស និងក្នុងការគ្រប់គ្រងពន្ធនាគារ។ កិច្ចសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារ (GDP) បានលេចចេញជារូបរាងផ្លូវការក្នុងឆ្នាំ២០០៨ តាមរយៈកម្មវិធីគាំទ្រកំណែទម្រង់ពន្ធនាគារ របស់ការិយាល័យ OHCHR ប្រចាំកម្ពុជា ដែលតាមរយៈកម្មវិធីនេះ ស្ថាប័នទាំងពីរបានធ្វើការងារ ដើម្បីកែលម្អស្ថានភាពពន្ធនាគារ បង្ការទារុណកម្ម និងការធ្វើបាប និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសេវាពន្ធនាគារ។

ក្នុងប្រទេសកម្ពុជា មានពន្ធនាគារចំនួន ២៣ កន្លែង និងមានមណ្ឌលអប់រំកែប្រែចំនួន ៤ កន្លែង ក្នុង ២៤ ខេត្ត ដែលអាចទទួលដាក់អ្នកទោសបានចំនួន ១៤.៧០០ នាក់ ដែលមាន ៣៨% ជាទណ្ឌិតមានសាលក្រមស្ថាពរ ២៣% ជាជនជាប់ឃុំបណ្តោះអាសន្ន ហើយ ៣៩% បានជនុំជម្រះនៅសាលាដំបូងរួចហើយ ប៉ុន្តែមិនទាន់មានសាលក្រមស្ថាពរ (រាប់ទាំងជនជាប់ឃុំដែលជាប់បណ្តឹងឧទ្ធរណ៍)។ ក្នុងចំណោមអ្នកទាំងនោះ ៨% ជាស្ត្រី និង ៣% ជាអនីតិជន។

នៅក្នុងអំឡុងឆ្នាំ ១៩៩៩-២០០០ ដោយតម្លៃដីធ្លីមានការកើនឡើង បានធ្វើឲ្យរាជរដ្ឋាភិបាល ត្រូវផ្លាស់ប្តូរទីតាំងពន្ធនាគារមួយចំនួនជាបន្តបន្ទាប់ទៅកាន់តំបន់ដាច់ស្រយ៉ាល ដែលពន្ធនាគារសាងសង់ថ្មីមួយចំនួនមានបំពាក់គ្រឿងបរិក្ខាតិចតួច មិនស្របតាមបទដ្ឋានអន្តរជាតិ។ ដោយលទ្ធភាពទទួលបានខ្យល់ធម្មជាតិ ទឹក និងអគ្គិសនី នៅមានកម្រិត ហើយប្រព័ន្ធលូរំដោះទឹកសំអុយ និងលូបង្ហូរទឹកមានសភាពចាស់ទ្រុឌទ្រោមខ្លាំង សុខភាពអ្នកទោស សូម្បីតែអ្នកដែលមានសុខភាពល្អបំផុត ក៏អាចនឹងធ្លាក់ខ្លួនចុះខ្សោយភ្លាមៗដែរ ហើយបន្ថែមពីលើនេះទៀតនោះគឺ ការដាក់អ្នកទោសច្រើនហួសចំណុះ។

ការជួយឧបត្ថម្ភរបស់ការិយាល័យ OHCHR បានចាប់ផ្តើមដោយការផ្តល់ការណែនាំដល់អគ្គនាយកដ្ឋានពន្ធនាគារ លើការជួសជុលកែលម្អអាគារចាស់ និងការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក និងប្រព័ន្ធអនាម័យថ្មី ដើម្បីបង្កើនលទ្ធភាពទទួលបានទឹកស្អាត និងលើកកម្ពស់អនាម័យ។ ជំនួយបែបនេះ គួបផ្សំជាមួយការឃ្លាំមើលតាមពន្ធនាគារ ដើម្បីផ្តល់ប្រឹក្សាយោបល់ផ្នែកគោលនយោបាយ ក៏ដូចជា ការតាមដានករណីបណ្តឹងនីមួយៗរបស់បុគ្គល។

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

ក្នុងអំឡុងពេលពេលចាប់ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៣ ការិយាល័យ OHCHR បានផ្តល់ជំនួយផ្នែកសម្ភារយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីកែលម្អស្ថានភាពទ្រុឌទ្រោមរបស់ពន្ធនាគារ។ ការិយាល័យ OHCHR បានដំឡើងម៉ាស៊ីនបូមទឹកមួយចំនួន និងសង់អាងស្តុកទឹកស្អាតសម្រាប់ទទួលទាន និងសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ផ្គត់ផ្គង់ប៉ាវខ្សាច់សម្រាប់ការពារទឹកជំនន់ (ដោយសារពន្ធនាគារជាច្រើនមានទីតាំងនៅតំបន់ដែលងាយទទួលរងគ្រោះដោយទឹកជំនន់) និងបានផ្តល់ ចបជីក និងចបកាប់ សម្រាប់ការងារកសិកម្ម និងសម្រាប់សំអាតលូបង្ហូរទឹក។ ផ្តល់សម្ភារផ្គត់ផ្គង់សម្រាប់អនាម័យផ្ទាល់ខ្លួន (ដូចជា សាប៊ូដុំ សាប៊ូម្សៅ ច្រាសដុសធ្មេញ និងថ្នាំដុសធ្មេញ) ដល់អ្នកទោសជាង ១៦.៥០០ នាក់។

ឧបសគ្គធ្លាប់មានចំពោះលទ្ធភាពទទួលបាន ខ្យល់ធម្មជាតិ និងពន្លឺព្រះអាទិត្យ នៅក្នុងពន្ធនាគារចាស់ៗ ធ្លាប់បណ្តាលឲ្យមានជំងឺសើរស្បែក ស្ថិតក្នុងអាកាសធាតុក្តៅសើមជាធម្មតានៅកម្ពុជា។ តាមអនុសាសន៍របស់ការិយាល័យ OHCHR អគ្គនាយកដ្ឋានពន្ធនាគារ បានយល់ព្រមរួមគ្នាបង្កើតឲ្យមានបង្អួច និង ទ្វារថ្មីចំនួន ១៩៥។ ដោយលទ្ធ ភាពអាចទទួលបានខ្យល់ធម្មជាតិ និងពន្លឺព្រះអាទិត្យច្រើនជាងមុន បច្ចុប្បន្ននេះ អ្នកទោសប្រឈមនឹងហានិភ័យនៃការកើតកមរមាស់ និង ជំងឺស្លឹកដៃជើងមានការថយចុះច្រើន។

ការិយាល័យ OHCHR បានជួយឧបត្ថម្ភដល់នាយកដ្ឋានសុខាភិបាល និងអគ្គនាយកដ្ឋានពន្ធនាគារ ធ្វើការជួសជុលកែលម្អបន្ទប់មន្ទីរពេទ្យ ចំនួន ២១ បន្ទប់ នៅមន្ទីរពេទ្យខេត្ត ដើម្បីធានាថាបន្ទប់ទាំងនោះមានសុវត្ថិភាព ដែលអាចទទួលយកអ្នកទោសដែលមានជម្ងឺចូលសម្រាកព្យាបាល ដោយមិនចាំចាច់ត្រូវដាក់ច្រវ៉ាក់ ឬដាក់ខ្នោះដៃឡើយ។ នៅពន្ធនាគារចំនួនបី ការិយាល័យ OHCHR បានជួយបើកបណ្ណាល័យ ដើម្បីឱ្យអ្នកទោសមានលទ្ធភាពទទួលបានឯកសារអប់រំ និងឯកសារសម្រាប់អានផ្សេងៗទៀត។ មតិត្រឡប់ដែលទទួលបានតាមរយៈកិច្ចសម្ភាសន៍ជាសម្ងាត់ ជាមួយអ្នកទោស អាចឲ្យការិយាល័យ OHCHR ផ្តល់អនុសាសន៍គោលដៅធ្វើការកែលម្អស្ថានភាពពន្ធនាគារ។ ក្នុងចំណោមអនុសាសន៍ទាំងនោះ មានការផ្តល់អាហារបន្ថែមជីវជាតិ ផ្គត់ផ្គង់ទឹកស្អាតសម្រាប់ទទួលទាន និងសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងអនាម័យល្អ ។ បច្ចុប្បន្ននេះ អ្នកទោស ត្រូវបានអនុញ្ញាតឲ្យចេញក្រៅបន្ទប់ឃុំឃាំង ដើម្បីយកខ្យល់ធម្មជាតិ រយៈពេលអប្បបរមា ១ ម៉ោង ក្នុងមួយថ្ងៃ ហើយក្នុងករណីខ្លះ អាចរហូតដល់ ៤ ម៉ោង ក្នុងមួយថ្ងៃក៏សឹងមាន។

ចាប់ពីឆ្នាំ២០១២ មក ដំណើរការធ្វើកំណែទម្រង់ពន្ធនាគារ បានប្រែក្លាយបន្តិចម្តងៗទៅ ជាងារការផ្ទៃក្នុង ក្នុងកម្មវិធីការងាររបស់អគ្គនាយកដ្ឋានពន្ធនាគារ។ ការងារជួសជុលកែលម្អរបស់អគ្គនាយកដ្ឋានពន្ធនាគារ នូវបន្ទប់ពន្ធនាគារចាស់ៗមួយចំនួន ក៏ដូចជា ការសាងសង់ ពន្ធនាគារថ្មី បានមកពីមេរៀននៃការធ្វើការងាររួមគ្នា ក្នុងការបំពេញតាមបទដ្ឋានអន្តរជាតិ។ នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ មិនមានករណីអះអាងអំពីការធ្វើទារុណកម្ម ត្រូវបានគេរាយការណ៍ឡើយ។

ទំនាក់ទំនងការងារជិតស្និទ្ធ ដែលបានបង្កើតឡើងជាមួយអគ្គនាយកដ្ឋានពន្ធនាគារ បានត្រួស

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

ត្រាយផ្លូវឲ្យមានការចូលរួមជាក់ស្តែងក្នុងការគ្រប់គ្រងពន្ធនាគារ។ ផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ២០១៤-២០១៨ របស់អគ្គនាយកដ្ឋានពន្ធនាគារ រួមបញ្ចូលបញ្ហាអាទិភាពជាច្រើនសម្រាប់ការធ្វើកំណែទម្រង់។ កិច្ចខិតខំប្រឹងប្រែង ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ បានចាប់ផ្តើមភ្លាមៗ។ សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងលើកលែងទោស ត្រូវបានតាក់តែងឡើង និងរៀបចំជាស្រេចសម្រាប់ការចូលរួមប្រជុំពិគ្រោះយោបល់ដ៏ទូលំទូលាយក្នុងចំណោមស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល។ ដោយមានការគាំទ្រពីការិយាល័យ OHCHR អគ្គនាយកដ្ឋានពន្ធនាគារ ទទួលបានជោគជ័យក្នុងការសម្រេចបានការអនុម័តអនុក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃមន្ត្រីពន្ធនាគារ ដែលបានផ្តល់ដល់មន្ត្រីពន្ធនាគារជាលើកដំបូងនូវលក្ខន្តិកៈវិជ្ជាជីវៈមួយ ដាច់ដោយឡែកពីកម្លាំងនគរបាល ហើយលក្ខន្តិកៈវិជ្ជាជីវៈនេះបានអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារ បង្កើតកម្មវិធីបណ្តុះបណ្តាជំនាញឯកទេស ឲ្យស្របទៅនឹងទំនួលខុសត្រូវរបស់ខ្លួន។

នៅក្នុងឆ្នាំ២០១៤ ការិយាល័យ OHCHR បានចាប់ផ្តើមផ្តល់កម្មវិធីបណ្តុះបណ្តាលមួយស្តីពី "វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាសំខាន់ សម្រាប់ការគ្រប់គ្រងពន្ធនាគារ"[1] ដល់ក្រុមគ្រូបង្គោលពន្ធនាគារដែលមកពីអគ្គនាយកដ្ឋានពន្ធនាគារ និងបណ្ឌិត្យសភានគរបាលកម្ពុជា។ តាមរយៈទស្សនកិច្ចសិក្សានៅតាមពន្ធនាគារផ្សេងៗ ដែលរៀបចំឡើងដោយ ការិយាល័យ OHCHR គ្រូបង្គោលទាំងនេះអាចគ្រប់គ្រងមន្ត្រី និងអ្នកគ្រប់គ្រងពន្ធនាគារ ដែលឆ្លងកាត់វគ្គបណ្តុះបណ្តាលហើយ នៅកន្លែងធ្វើការងារ និងធ្វើការវាយតម្លៃពីសេចក្តីត្រូវការសម្រាប់ការបណ្តុះបណ្តារបស់ពួកគេ។ គ្រូបង្គោលទាំងនេះ បានរួមគ្នាពិនិត្យឡើងវិញនូវវិធីសាស្ត្របណ្តុះបណ្តាល និងកម្មវិធីសិក្សា។ មតិត្រឡប់មានលក្ខណៈវិជ្ជមានច្រើន ដែលអាចចាត់ទុកជាការងារជាប្រចាំមួយ ក្នុងការបណ្តុះបណ្តាលជាកាតព្វកិច្ច សម្រាប់មន្ត្រីពន្ធនាគារទើបចូលថ្មីទាំងអស់។

ពិតណាស់ មានកិច្ចការជាច្រើនដែលត្រូវធ្វើ ដើម្បីឲ្យពន្ធនាគារកម្ពុជាឈានដល់កម្រិតបទដ្ឋានអន្តរជាតិ។ ផ្នែកមួយដែលនៅសេសសល់ ក្នុងប្រព័ន្ធអនុវត្តច្បាប់ គឺការខ្វះធនធានយ៉ាងច្រើន ដូចជាការពាក់ព័ន្ធនឹងអំពើពុករលួយ និងដោយមិនមានប្រព័ន្ធឃ្លាំមើលថ្នាក់ជាតិឯករាជ្យណាមួយ។ ការដាក់អ្នកទោសច្រើនលើសចំណុះក្នុងពន្ធនាគារ និងការឃុំខ្លួនដោយបំពាន មិនទាន់ត្រូវបានបំបាត់នៅឡើយទេ។ ស្ថិតក្នុងតថភាពជាក់ស្តែងនេះ វិធីសាស្ត្រពហុវិស័យនៃកម្មវិធីគាំទ្រកំណែទម្រង់ពន្ធនាគាររបស់ការិយាល័យ OHCHR បាននាំមកនូវ ការប្រព្រឹត្ត ទៅលើអ្នកទោសប្រកបដោយលក្ខណៈមនុស្សធម៌ថែមទៀត ដែលអាចចាត់ទុកថាជាសមិទ្ធិផលដ៏អស្ចារ្យបំផុតមួយក្នុងចំណោមសមិទ្ធិផលនានារបស់ការិយាល័យ OHCHR ប្រចាំកម្ពុជា។

---

[1] ផ្អែកភាគច្រើនលើកូនសៀវភៅដែលមានចំណងជើងនេះ ដែលបាននិពន្ធដោយ អេនជ្រូ ខ័យលី (Andrew Coyle) បោះពុម្ពដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាពីពន្ធនាគារ (២០០៩) ទីក្រុងឡុងដ៍។